**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៧២ប្រ
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៩

**សាលដីកា**
លេខ:៩៥ប្រ
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៩

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............. ជាចៅក្រមរបាយការណ៍
៤-លោក ............... ជាចៅក្រម
៥-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ..................

**តំណាងមហាអយ្យការ**
-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៣២ ចុះថ្ងៃទី៦-០២-៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៨៧ ចុះថ្ងៃទី១៧-១២-៩៧ របស់សាលាឧទ្ធរណ៍

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះអបហ ភេទប្រុសអាយុ៥៣ ឆ្នាំ និងឈ្មោះអលបបសភេទស្រីសញ្ជាតិបារាំង ទីលំនៅផ្ទះលេខ៣៧៩ វិថីស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីឈ្មោះ............ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះបណហប ភេទប្រុស អាយុ៣៥ឆ្នាំជាតិបារាំងមុខរបរនាយកក្រុមហ៊ុន រ៉ូតុនក្លឹប ទីលំនៅផ្ទះលេខ៣៩H ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិឱ្យលោកម្ចង សុទ្ធី ទីប្រឹក្សាច្បាប់ស្ថានទូតបារាំង ។

**<u>កម្មវត្ថុបណ្តឹង</u>** សុំដីកាសម្រេចកិច្ចការប្រញាប់ផ្អាក់ការស្នាក់នៅនឹងធ្វើអាជីវកម្មភោជនីយដ្ឋាន ឡារ៉ូតុន និងសុំបន្តអាជីវកម្មភោជនីយដ្ឋានឡារ៉ូតុន ដោយនាយកក្រុមហ៊ុនឈ្មោះ ប្រុយណូហ្សូមប៊ុត ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៦ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់លោក ដារីញ៉េល ការីលី តំណាងឱ្យឈ្មោះ អ៊ីល ប៊ុយហ្វា បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលដីកាលេខ៣២ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៧២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២១-១១-១៩៩៧ របស់ឈ្មោះបណហប(Bruno Jambut) ដែលមានលោកម្ចង សុទ្ធី ភេទប្រុស អាយុ៣៦ឆ្នាំ ប្តឹងសុំហាមឃាត់ឈ្មោះអ៊ីល ប៊ុយហ្វា និងលោកស្រីអេលី ប៊ូបិស្សុង( ELIE BOBICHON) ឱ្យផ្អាក់ការស្នាក់នៅ និងធ្វើអាជីវកម្មលើភាជនីដ្ឋានឡារ៉ូប៊ូតុង(LAROTONDE)ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន រ៉ូតុងក្លឹប ដែលមាន

ទីតាំងផ្ទះលេខ៣៧៩ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញក្រុងភ្នំពេញ ដោយគ្មានការអនុញ្ញាត្តិពីប្រធានក្រុមហ៊ុន និងសមាជិកក្រុមហ៊ុន និងសុំឱ្យបើកបន្តក្រុមហ៊ុន រ៉ូតុងក្លឹប ដោយទារយកក្រុមហ៊ុនឈ្មោះប្រុយណូ ហ្សមប៊ុត( Bruno Jambut) ជាបណ្តោះអាសន្នសិន ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ៣១ *ក* ចុះថ្ងៃទី២១-១១-៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ឈ្មោះប្រុយណូ ហ្សមប៊ុត(Bruno Jambut ) ចុះថ្ងៃទី២១-១១-៩៧ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ហាមឃាត់ឈ្មោះអ៊ូ ប៉ុយហ្វា និងអ្នកស្រី អេលី បូបីស្យុង ផ្អាក់ការស្នាក់នៅ និងធ្វើអាជីវកម្មភោជនីយដ្ឋាន ឡារ៉ូតុង(La Rotonde) និងមិនឱ្យយកទ្រព្យសម្បត្តិរបស់របរ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនចេញពីក្រុមហ៊ុនរ៉ូតុងក្លឹបជាបណ្តោះអាសន្នរង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៣- អនុញ្ញាតិឱ្យឈ្មោះប្រុយណូ ហ្សប៊ុយ ( Bruno Jambut) ដែលជានាយកក្រុមហ៊ុន រ៉ូតុងក្លឹប បើកដំណើរការលើក្រុមហ៊ុន រ៉ូតុងក្លឹប ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៤. បង្គាប់ឱ្យឈ្មោះប្រុយណូ ហ្សមប៊ុយ ( Bruno Jambut) បង់ប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជី ពន្ធហ្វឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហើបប្រាក់ ២០០រៀល សរុប ២០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៥-បើភាគីណាពុំសុខចិត្តនិងដីកានេះ មានសិទ្ធិប្តឹងជំទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដីកាសម្រេចនេះ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ៥៣ប្រ.ក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១-១២-៩៧ របស់ឈ្មោះដីវ សាន តំណាងឱ្យឈ្មោះអ៊ី ប៉ុយហ្វា និងអ្នកស្រីអេលី បូប៊ូស្យុង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុស និង គតិច្បាប់ ។

២- តម្កល់ដីកាសម្រេចតាមពាក្យសុំលេខ៣១ *ក* ចុះថ្ងៃទី២១-១១-៩៧ ទុកជាបានការតាមច្បាប់។

៣- បង្គាប់ឱ្យឈ្មោះដីវ សាន បង់ប្រាក់ប្រដាប់ក្តីចំនួន២០០០រៀល គឺពន្ធចុះបញ្ជី និងពន្ធហ្វឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហើបប្រាក់២០០រៀល សរុប២០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់២០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤- ដីកាសម្រេចនេះ មានអនុភាពយកទៅអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញបណ្តឹងឧទ្ធរណ៍លខ ៩៣ *ក* ចុះថ្ងៃទី១១-១២-៩៧ របស់លោកដីវ សាន ដែលប្តឹងជំទាស់នឹងដីកាសម្រេចកិច្ចការប្រញាប់លេខ៥៣ ប្រ.ក ចុះថ្ងៃទី០៥-១២-១៩៩៧ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចកិច្ចការប្រញាប់ទាំងមូល ។

បានឃើញសាលដីកាកំបាំងមុខរដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-១២-៩៧ របស់មេធាវីការពារចុងចម្លើយឈ្មោះដីវ សាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២- តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ៥៣ប្រ.ក ចុះថ្ងៃទី០៥-១២-៩៧ របស់តុលាការក្រុងភ្នំពេញទុកជាបានការ ។

៣- សម្រេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើ ការប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ។ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៦ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់លោកដារីញ៉ែល ការីលី តំណាងឱ្យឈ្មោះលោកអ៊ីល ប៊ុយហ្វា បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៣២ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី០៦-៤-១៩៩៨ របស់លោក............ (ជាតំណាងឱ្យលោកអ៊ី ប៊ុយហ្វា )

បានឃើញសារណាតប ចុះថ្ងៃទី០២-៦-១៩៩៨ របស់លោកមួង សុទ្ធី

បានស្តាប់របាយការណ៍ របស់ទៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការះ

-សាលាឧទ្ធរណ៍ក៏ដូចតុលាការក្រុងភ្នំពេញដែរដែលសម្រេចហាមឃាត់ឈ្មោះអបហ និងអ្នកស្រីអេលី ប៊ូប៊ីស្យុង ផ្អាក់ការស្នាក់នៅ និងការធ្វើអាជីវកម្មលើភោជនីយដ្ឋានឡារ៉ូតុង និងអនុញ្ញាតឱ្យលោកប្រ៊ុយណូ ហ្សមប៊ុយ បើកដំណើរការលើក្រុមហ៊ុនឡារ៉ូតុង ជាបណ្តោះអាសន្ននោះជាការបំពានទៅនិងគោលការណ៍ដីកាសម្រេចកិច្ចការប្រញាប់តម្រូវ ឱ្យអ្នកដែលកំពុងប្រើប្រាស់ របស់ដែលខ្លួនប្រើនោះបន្តសិន ដោយធ្វើការហាមឃាត់ការលក់ ឬធ្វើឱ្យបាត់បង់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីអានសារណារបស់មេធាវីឈ្មោះ............ ជាតំណាងឱ្យលោក អបហ ។

បានស្តាប់ចម្លើយរបស់ឈ្មោះមួង សុទ្ធី ជាដើមចោទ និងជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា៖ កូនក្តីខ្លួនបើកក្រុមហ៊ុនត្រូវបានក្រសួងពាណិជ្ជកម្មអនុញ្ញាតិ ក្រោយពីផ្អាកបណ្តោះអាសន្នឈ្មោះអបហ និងអ្នកស្រី អេលីប៉ូប៊ីស្យុង លួចបើកយកកំរៃផ្ទាល់ខ្លួន ឯថ្លៃចំណាយផ្សេងប្រចាំខែឱ្យខ្លួនចេញទៅវិញ ក្រោយមកកូនក្តីខ្លួនឈប់បង់ថ្លៃផ្ទះទើបលោកមិន យិន ដកយកផ្ទះវិញ ចាំតុលាការសម្រេចព្រោះនៅមានសំភារៈក្នុងផ្ទះ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ពៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សចក្តីសន្និដ្ឋាន របស់ណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់លោកប៊ុច វិច្ឆិកា មេធាវីលោកអបហ និង ចម្លើយរបស់លោកមួង សុទ្ធី តំណាងឱ្យលោកប្រុយណូ ហ្សមប៊ុត.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៦ ចុះថ្ងៃទី ១២-៣-៩៨ របស់លោក ដានីញ៉ែល ការីលី តំណាងឱ្យលោកអ៊ី ប៊ុយហ្វា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការក្រុងភ្នំពេញដែរ ដែលសម្រេចឱ្យលោកអបហ និងអ្នកស្រី អេលី ប៉ូប៊ីស៊ុង ផ្អាកការស្នាក់នៅ និងធ្វើអាជីវកម្មលើភោជនីយដ្ឋានឡារ៉ូតុង ហើយអនុញ្ញាតឱ្យលោកអ៊ីវ ប្រុយណូ ហ្សមប៊ិត បើកដំណើរការក្រុមហ៊ុនឡារ៉ូតុងជាបណ្ដោះអាសន្ននោះជា ការបំពានទៅនឹងគោលការណ៍នៃកិច្ចការប្រញាប់ ពីព្រោះថា តាមគោលការណ៍ដីកាសម្រេចកិច្ចការប្រញាប់ តែងតម្រូវឱ្យអ្នកកំពង់ប្រើប្រាស់ថែរក្សារបស់អ្វីមួយឱ្យ បន្តប្រើប្រាស់ និងថែរក្សារបស់នោះជាបណ្ដោះអាសន្នបន្តទៀត ដោយហាមឃាត់ការចាត់ចែងផ្សេងៗ ហើយបើចាំបាច់ តម្រូវឱ្យមានបញ្ជីកត់ត្រា ឬបញ្ជីគណនេយ្យត្រឹមត្រូវ ។

-យល់ឃើញថា លោកអបហ ដែលមានលោកប៊ុច វិច្ឆិការ ជាមេធាវីបានធ្វើសារណាការពារ រឿងក្ដីរបស់លោក ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថាការដែលតំណាងដើមចោទលើកឡើងអំពីសិទ្ធិប្ដឹងសាទុក្ខរបស់លោកដានីញ៉ែល ការីលី នោះពុំបានជូនភស្តុតាងណាមួយដែលអាចឱ្យទុកជាមោឃៈលើខិតផ្ទេរសិទ្ធិចុះថ្ងៃទី០១-១២-៩៧របស់លោកអ៊ីប៊ុយហ្វាបានឡើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ៦-២-៩៨ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**និច្ឆ័យសេចក្ដីចំពោះមុខលោក មួង សុទ្ធី តំណាងឱ្យ ប្រ៊ុយណូ ហ្សមប៊ិត កំបាំងមុខ លោកអបហ និង មេធាវីរបស់លោក ប៉ុន្តែចាត់ទុកជាចំពោះមុខ.**

១- ទទួលបណ្ដឹងសាទុក្ខលេខ៥៦ ចុះថ្ងៃទី១២-៣-៩៨ របស់លោកដានីញ៉ែល ការីលី តំណាងឱ្យលោកអបហ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី៦-២-៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- លើកបណ្ដឹងចុះថ្ងៃទី២១-១១-៩៧ របស់លោកប្រ៊ុយណូ ហ្សមប៊ិត ចោលជាអសារបង់ ។

៤- បញ្ជូនសំណុំរឿងកិច្ចការប្រញាប់លេខ៧២ ចុះថ្ងៃទី២៣-៣-៩៨ របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងសំណុំរឿង នៃអង្គសេចក្ដី ។

៥- រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០រៀល ដែលម្ចាស់បណ្ដឹងសាទុក្ខបានបង់រួចហើយគឺ ៖

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ។

ហើយតម្រូវឱ្យលោកប្រ៊ុយណូ ហ្សមប៊ិត សងប្រាក់ ១៩.០០០រៀល នេះទៅលោកដានីញ៉ែល ការីលី វិញ ។

៦-សាលដីកានេះ ប្រកាសនាសនាការ ជាសាធារណៈ នៅថ្ងៃទី២៥-០៥-៩៩ ។